# THE USE OF THE PRESENT AND PAST TENSES

(របៀបប្រើរបស់ PRESENT TENSES និង PAST TENSES)

## PRESENT TENSES

### *Simple Present Tenses*

217. The Simple Present is used:--

២១៧. Simple Present ត្រូវបានគេប្រើ:

(1) To express a habitual action; as,

(១) សំរាប់បញ្ជាក់ពីទំលាប់

He *drinks* tea *every morning*. គាត់ផឹកតែរាល់ព្រឹក។

ពាក្យ very morning ប្រាប់ពីទំលាប់។

I *get up everyday* at five o'clock. ខ្ញុំក្រោកពីដេកនៅម៉ោង៥រាល់ថ្ងៃ។

ពាក្យeverydayប្រាប់ពីទំលាប់។

My watch *keeps good* time. នាឡិកាខ្ញុំដើរទៀងម៉ោង។

(2) To express general truths; as,

(២) បញ្ជាក់ពីការពិតទូទៅ ដូចជា

The sun *rises* in the east. (ការពិតទូទៅតាមក្រិតក្រមធម្មជាតិ)

ព្រះអាទិត្យរះនៅទិសខាងកើត។

Honey is sweet. ទឹកឃ្មុំផ្អែម។

Fortune *favours* the brave. (Proverb)

អ្នកហ៊ានប្រថុយតែងតែមានសំណាង។

(3) In exclamatory sentences beginning with *here* and *there* to express what is actually taking place in the present; as,

(៣) នៅក្នុងឃ្លាឧទានស័ព្ទដែលផ្តើមឡើងដោយពាក្យ here និង there ដើម្បីបញ្ជាក់ពីអ្វីដែលកំពុងកើតឡើងពិតប្រាកដនៅក្នុងពេលបច្ចុប្បន្ន ដូចជា

*Here* comes (V) the bus (N (S))! នោះឡានក្រុងមកហើយ! (កាលណាជា Noun ទើបត្រឡប់ Subject)

*Here* it (pron) comes (Verb)! នោះវាមកហើយ! (Subject ជា Pronoun មិនត្រឡប់ Subject ទេ)

NOTE: ~~Here the bus comes!~~ (WRONG)

Here ប្រើសំរាប់ចលនា(ចូល)មក

There ប្រើសំរាប់ចលនាចេញទៅ

There goes the motor-taxi! នោះម៉ូតូឌុបទៅស្រេច!

Bicycle-taxi = កង់ឌុប

Boat-taxi = ទូកចំលង(ពីម្ខាងទៅម្ខាង)

Come ប្រើសំរាប់ចលនាមក

Go ប្រើសំរាប់ចលនាចេញទៅ

There she goes! នោះគាត់ទៅហើយ!

(4) In vivid narrative, as substitude for the Simple Past; as,

(៤) នៅក្នុងការអត្ថាធិប្បាយជាក់ស្តែង/យ៉ាងច្បាស់ជាការប្រើជំនួស Past Simple (និយាយរឿង) ដូចជា

Sohrabឥឡូវនេះរត់សំរុកទៅមុខហើយវាយមួយដៃយ៉ាងដំណំទៅលើRustum។

To rush = ធ្វើដំណើរយ៉ាងលឿន/រត់យ៉ាងលឿន

www.salarean.com

To rush forward = រត់សំរុកទៅមុខ/ស្ទុះទៅមុខ

| | |
|---|---|
| To deal<br>To driver | a blow to sb/sth = វាយសំពងទៅលើ |

| | | |
|---|---|---|
| a | heavy<br>stunning<br>telling | blow = ការវាយសំពងយ៉ាងដំណំ |

Immediately the Sultan hurries to his capital.

ភ្លាមនោះស្តេចស៊ុលតង់ក៏ប្រញាប់ទៅរាជធានី។

Note: 1- សំរាប់ការអត្ថធិប្បាយពីរឿងដែលកើតឡើងក្នុងអតីតកាលហើយដើម្បីធ្វើឲ្យរឿងហ្នឹងហាក់ដូចជាកំពុងកើតឡើង។

2- គេប្រើសំរាប់អត្ថាធិប្បាយពីអំពើកំពុងកើតឡើងដំណាលការនិយាយ

ឧ. ពេលអុំទូក, វៃបុក, បាល់ទាត់, ......

(ប្រើPresent Simple និង Present Continous)

- ពេលកំពុងបណ្តើរបាល់ជាអំពើវែង ប្រើ Present Continous

- ពេលទាត់បាល់ជាសកម្មភាពSingle ប្រើ Present Simple

(5) To express a future event that is part of a fixed timetable or fixed programme; as,

(៥) ប្រើសំរាប់បញ្ជាក់ពីហេតុការណ៍អនាគតដែលជាផ្នែកមួយនៃកាលវិភាគ ឬ កម្មវិធីឥតផ្លាស់ប្តូរ ដូចជា

To be part of = ជាផ្នែកមួយនៃ

As part of (prep) = ជាផ្នែកមួយនៃ

| | | |
|---|---|---|
| Fixed | timetable<br>schedule | = កាលវិភាគដែលឥតផ្លាស់ប្តូរ |

The next flight is at 7.00 tomorrow morning.

ជើងហោះហើរលើកក្រោយគឺម៉ោង៧ព្រឹក។

The match starts at 9 o'clock.

ការប្រកួតចាប់ផ្តើមនៅម៉ោង៩។

The train leaves at 5.20.

រថភ្លើងចាកចេញនៅម៉ោង5.20នាទី។

When does the coffee house reopen?

តើហាងកាហ្វេបើកនៅម៉ោងប៉ុន្មាន?

208. Note also the other uses of the Simple Present Tense.

២០៨. ចូរកត់សំគាល់ផងដែរពីរបៀបប្រើផ្សេងៗទៀតរបស់ Present Tense។

(1) It is used to introduce quotations; as,

(១) គេប្រើសំរាប់ផ្តើមសេចក្តី/សំដីដកស្រង់ ដូចជា

Keats says, 'A thing of beauty is a joy for every.'

Keats និយាយថា អ្វីដែលមានសំរស់គឺជាការរីករាយជារៀងរហូត ។

(2) It is used, instead of the Simple Future Tense, in clauses of time and of condition; as,

(២) វាប្រើជំនួស Simple Future Tense នៅក្នុង Adverb of Time និង Condition ដូចជា

I will wait. You will finish (Future Simple) your lunch. (Future Simple) ខ្ញុំនឹងរង់ចាំ។ អ្នកនឹងញ៉ាំបាយរួច។

www.salarean.com

I will wait (Main Clause) *until* you finish (Present Simple) your lunch. (Sub–clause of time) (Present Simple)

until ជាConjunction ប្រាប់ពេលវេលា

Clause ដែលនាំមុខដោយ Clause marker (ពាក្យសំគាល់ន័យ) ឃ្លានោះ គឺជាប្រយោគរណប។

*Conjunctions of time and condition:*

Until, till, when, while, as soon as, once, before, after, etc.

It *will rain* (Future Simple). We get wet.

↓

If *it rains* (Present Simple), we will get wet. បើភ្លៀងយើងនឹងទទឹកជោគ។

ការផ្លាស់ប្តូរកាល

1. Future Simple ប្តូរទៅជា Present Simple
2. Future Progressive ប្តូរទៅជា Present Progressive
3. Future Perfect ប្តូរទៅជា Present Perfect

I will wait. You *will have finished* (Future Perfect) your lunch.

↓

=> I will wait *until* *you have finished* (Present Perfect) your lunch.

(3) As in broadcast commentaries on *sporting events*, the Simple Present is used, instead of the Present Continous, to describe activities in progress where there is stress on the *succession of* happenings rather than on the duration.

(3) ដូចនៅក្នុងការផ្សាយអត្ថាធិប្បាយស្តីពីវិញ្ញាសាកីឡា Present Simple ត្រូវបានគេប្រើជំនួស Present Continous ដើម្បីពិពណ៌នាអំពីសកម្មភាពកំពុងកើតឡើងដែលនៅក្នុងនោះមានការសង្កត់សំលេងធ្ងន់ទៅលើហេតុការណ៍កើតជាបន្តបន្ទាប់ជាជាងទៅលើរយៈពេល។

Commentaries = ការអត្ថាធិប្បាយ

in progress = កំពុងកើតឡើង

sporting event = វិញ្ញាសាកីឡា

happening = ព្រឹត្តិការណ៍ដែលកើតឡើង

broadcast = ការផ្សាយ(តាមវិទ្យុ)

A succession of + plural noun = ជាបន្តបន្ទាប់

e.g. *a succession* / *successive* | of victories = ជ័យជំនះជាបន្តបន្ទាប់

(4) The Simple Present is used, instead of the Present Continous, with the type of verbs referred to in (§ 221) below.

(4) Present Simple ត្រូវបានគេប្រើជំនួស Present Continous ជាមួយប្រភេទ Verbs ដែលគេនិយាយនៅក្នុងលេខ 221 ខាងក្រោម។

www.salarean.com

# *PRESENT CONTINOUS TENSE*

219. The Present Continous is used

219. Present Continous ត្រូវគេប្រើ

***ប្រើសំរាប់អំពើកើតឡើងនៅពេលកំពុងនិយាយ

***ប្រើសំរាប់អំពើកំពុងកើតឡើងនៅពេលបច្ចុប្បន្ន (មិនចាំបាច់កើតឡើងពេលកំពុងនិយាយទេ)




(1) For an action going on at *the time of speaking*; as,

(1) ប្រើសំរាប់អំពើមួយដែលកំពុងបន្តនៅពេលកំពុងនិយាយ ដូចជា

the time of speaking = ពេលកំពុងនិយាយ

She *is singing* (now). គាត់កំពុងច្រៀង (ច្រៀងឥឡូវហ្នឹង)។

The boys *are playing* hockey. ក្មេងៗកំពុងលេងកីឡា Hockey។

(2) For a temporary action which may not be actually happening at the time of speaking; as,

(2) សំរាប់អំពើបណ្តោះអាសន្នដែលអាចជាទូទៅមិនកើតឡើងនៅពេលកំពុងនិយាយ ដូចជា

I am reading 'David Copperfielf' (but I am not reading at this moment).

ខ្ញុំកំពុងអានសៀវភៅ David Copperfield (ប៉ុន្តែពេលនិយាយអត់អានទេ)។

(3) For an action that has already been arranged to *take place* *in the near future*; as, (Future Arragement)

***ប្រើសំរាប់អំពើដែលនឹង*កើតឡើង*នៅពេលអនាគត។

(3) សំរាប់អំពើមួយដែលគេបានរៀបចំទុកជាស្រេចទៅហើយឲ្យវាកើតឡើងនៅក្នុងពេលអនាគតដ៏ខ្លី។

to take place = កើតឡើង

in the near future = ក្នុងពេលអនាគតដ៏ខ្លី

I *am going* to the cinema tonight. ខ្ញុំនឹងទៅមើលកុនយប់នេះ។

going to នេះគឺ Present Continous របស់ Verb 'go' មិនមែន be going to ទេ។

My uncle is arriving tomorrows. ឪពុកមាខ្ញុំនឹងមកដល់នៅថ្ងៃស្អែក។

220. It has been pointed out before that the Simple Present is used for a habitual action. However, when the reference is to a particularly obstinate habit – sometime which persists, for example, inspite of advice or warming – we use the Present Continous with an adverb like always, continually, constantly.

220. គេបានគូសបញ្ជាក់ពីមុនរួចហើយថា Present Simple ត្រូវបានគេប្រើសំរាប់អំពើជាទំលាប់។ ប៉ុន្តែនៅពេលការនិយាយហ្នឹង គឺសំដៅទៅរកទំលាប់ចចេសរឹងរូសពិសេសអ្វីមួយនោះ គឺអ្វីដែលនៅតែមាន ឧទាហរណ៍ ទោះបីជាមានការទូន្មាន ឬ ការព្រមានយ៉ាងណាក៏ដោយ--នៅពេលយើងនិយាយទំលាប់អញ្ចឹងយើងប្រើកាល Present Continous ជាមួយ Adverb: Always, Continually, Constantly។

| | | |
|---|---|---|
| Present Continuous + | *always*<br>*continually*<br>*constantly* | = មិនស្វាង / ជានិច្ច / រហូត |

*reference* (*Noun*) + *to sth* (*Prep Phrase*) = *Noun Phrase*

www.salarean.com

(1) reference *to sth*

(2) *The reference* *is* *to sth.* ការនិយាយ(យោង) គឺ(និយាយ) សំដៅទៅរក......

*be*

...... *a particularly destinate habit – sth which persists in spite of advice ......*

*ADV + ADJ* — *Pron + ADJ*

*ADJ Phrase + Noun*

*Noun Phrase + Noun Phrase (Apposition)*

*Noun Phrase*

...... ទំលាប់ដ៏ចចេសរឹងរូសជាពិសេសមួយ គឺអ្វីដែលនៅតែមានទោះបីជាមានការផ្តល់ដំបូន្មានក៏ដោយ......

in spite of (prep) = ទោះបីជា

persist = នៅតែមាន

*wish* *for sth* = បំណងប្រាថ្នាចង់បានអ្វី១

*Noun* *Prep Phrase*

*បំពេញឲ្យ noun*

*His wish* *for happiness never realised.*

*Noun + Prep Phrase*

*Noun Phrase (Subject)*

បំណងប្រថ្នារបស់គាត់ដែលចង់បានសុភមង្គលមិនដែលសំរេចបានទេ។

*His wish was for happiness.* បំណងប្រាថ្នារបស់គាត់គឺចង់បានសុភមង្គល។

*Noun* *be* *Prep Phrase*

*ជា Prep របស់ reference*

*** *The reference is to sth.*

*Noun* *be* *Prep Phrase*

e.g. You are always complaining about food.

អ្នកឯងរអ៊ូជានិច្ច / មិនស្វាង អំពីម្ហូបហ្នឹង។

My dog is very silly; he is always running out into the road.

ឆ្កែរបស់ខ្ញុំឆ្កួត/ភ្លីមែន វាហ្នឹងរត់ចេញមកផ្លូវមិនស្វាងតែម្តង។

221. The following verbs, on account of their meaning, are not normally used in the continuous forms:--

221. Verbខាងក្រោមដោយសារតែអត្ថន័យរបស់វា តាមធម្មតាមិនត្រូវគេប្រើនៅក្នុងទំរង់ Continuous ទេ:

(1) Verbs of perception, e.g. see, hear, smell, notice, recognize.

(1) ពួក Verbដែលដឹងដោយអារម្មណ៍ ឧ. see, hear, smell (ធំក្លិន), notice, recognize។

| | | | |
|---|---|---|---|
| Verb of | *sensation*<br>*perception*<br>*sense perception* | = | *see, hear, watch, listen, smell, laste, recognize,*<br>*notice, observe, etc* |

(2) Verbs of appearing, e.g. appear, look, seem, sound.

(2) Verbs ដែលបង្ហាញអាការៈ ឧ. appear (ហាក់ដូចជា), look (មើលទៅដូចជា), seem (ហាក់ដូចជា), sound (ស្តាប់ឮ/មើល ទៅដូចជា)

(3) Verbs of emotion, e.g. want, wish, desire, feel, like, love, hate, hope, refuse, prefer

(3) Verbs ដែលបញ្ជាក់ពីអារម្មណ៍ ឧ. want, wish (មានបំណងប្រាថ្នា), desire (មានបំណងប្រាថ្នា), feel (មានអារម្មណ៍), like (ចូលចិត្ត), love, hate, hope, refuse (បដិសេធ), prefer។

(4) Verbs of thinking, e.g. think, suppose, believe, agree, consider, truth, remember, forget, know, understand, imagine, mean, mind.

www.salarean.com

(4) Verbs ដែលទាក់ទងនិងការគិត ឧ. think, suppose (គិត), believe, agree, consider (ពិចារណា), truth (ទុកចិត្ត), remember, forget, know, understand, imagine (ស្រម៉ៃ), mean (មានគោលបំណង), mind (ជំទាស់, ប្រើជាបដិសេធនិងសួរ)។

(5) have (= possess), own, possess, belong to, contain, consist of, be (except when used in the passive)

(5) have (មាន), own (កាន់កាប់/មាន), passess (មាន), belong to (មានជាកម្មសិទ្ធិ), contain (មានចំណុះ), consist of [មាន(សមាសភាព)], be (លើកលែងតែនៅពេលដែលគេយកទៅប្រើក្នុងទំរង់ Passive [being ក្នុង Present Continuous Passive Voice, Past Continuous Passive Voice, Future Continuous Passive Voice]

e.g. $\underbrace{to\ have}_{Empty\ Verb} \left| \begin{array}{l} a\ book \\ a\ drink \\ breakfast \end{array} \right.$

| Wrong | Right |
|---|---|
| These grapes *are testing* sour. | These grapes taste soure.<br>ផ្លែទំពាំងបាយជូរទាំងអស់នេះមានរសជាតិជូរ។<br>(បញ្ជាក់ពីសភាព [state]) |
| I *am thinking* you are wrong. | I *think* you are wrong. |

to think + that = យល់ថា / គិតថា / មានយោបល់ (គិតក្នុងន័យយល់ឃើញឬមានយោបល់)

(អត់ប្រើ -ing formទេ)

to think + of doing sth = គិត (ក្នុងន័យពិចារណា) (ប្រើជា -ing form បាន)

e.g. I am thinking of moving to Phsar Deum Kor.

ខ្ញុំកំពុងគិតពីរឿងរើផ្ទះទៅនៅផ្សារដើមគរ។

NOT: ~~I am thinking that~~......

I think that......

to smell + adj = ធុំក្លិន (អត់ប្រើ -ing form ទេ) គេហៅ state verb

to smell + sth = ហិតក្លិន(ប្រើ -ing form គេហៅ action verb

to taste + adj = មានរសជាតិ (អត់ប្រើ -ing form)

to taste +sth = ភ្លក់

| Wrong | Right |
|---|---|
| She *is seeming* sad. | She *seems* sad. |
| He *is having* a cellular phone. | He *has* a cellular phone. |

However, the verbs listed above can be used in the continuous tense with a change of meaning:

ប៉ុន្តែ Verb ដែលគេរាយឈ្មោះខាងលើអាចប្រើនៅក្នុងកាលទំរង់ Continuous ដោយមានការផ្លាស់ប្តូរអត្ថន័យ:

She *is tasting* the soup to see if it needs more salt.

គាត់កំពុងភ្លក់សំឡដើម្បីដឹងថាតើវាត្រូវការដាក់អំបិលថែមទៀតឬអត់។

(taste = test the flavor of) Flavour = រសជាតិ

I *am thinking* of going to Malaysia.

ខ្ញុំកំពុងគិតមើលពីរឿងទៅប្រទេសម៉ាឡេស៊ី។

(think of = consider the idea of [ពិចារណាមើលពីគំនិតដែលថា)]

They *are having* lunch. (have = eat)

www.salarean.com

# PRESENT PERFECT TENSE

222. The Present Perfect is used:

222. Present Perfect ត្រូវគេប្រើប្រាស់:

(1) To indicate completed activitied in the immediate past (with just);as,

(1) ប្រើសំរាប់បញ្ជាក់ពីសកម្មភាពដែលចប់នៅក្នុងពេលអតីតកាលដែលទើបកន្លងទៅថ្មី (ជាមួយពាក្យ just) ដូចជា




I *have just had* dinner. ខ្ញុំទើបញ៉ាំបាយល្ងាចរួចហើយអំបាញ់មិញ។

He *has just gone* out. គាត់ទើបចេញទៅក្រៅបាត់អំបាញ់មិញនេះ។

It *has just struck* ten. នាឡិកាហ្នឹងទើបតែវាយម៉ោង១០។

(2) Tp express past action whose time is not given and not definite; as,

(2) ប្រើសំរាប់បញ្ជាក់អំពើក្នុងអតិតកាលដែលពេលវេលារបស់វាគេមិនប្រាប់ឬមិនច្បាស់លាស់ ដូចជា




e.g. I *have already had* dinner. ខ្ញុំញ៉ាំបាយល្ងាចរួចហើយ។

***ប្រើ Present Perfect មកពីអត់ពេលវេលា ប៉ុន្តែបើយើងប្រាប់ពេលវេលាច្បាស់លាស់ប្តូរវាទៅជា Past Simple វិញ។

I *had* dinner *at 5:30*. (Past Simple)

***Present Perfect និង Past Simple ដូចគ្នាត្រង់ ប្រើសំរាប់អំពើកើតចប់ក្នុងអតីតកាល។ ហើយខុសគ្នាត្រង់ថា Past Simple កើតចប់ក្នុងអតីតកាលមានពេលវេលាច្បាស់លាស់ ហើយ Present Perfect កើតចប់ក្នុងអតីតកាលមិនមានពេលវេលាច្បាស់លាស់។

Have you read 'Gulliver's Travels'?

តើអ្នកមានបានអានសៀវភៅ Gulliver's Travels ហើយឬនៅ?

I have never known him to be angry.

ខ្ញុំមិនដែលដឹងថាគាត់ខឹងទេ។

Mr. Hari *has been* to Japan.

លោក Hari ធ្លាប់ទៅជប៉ុន។

(3) To describe past events when we think more *of their effect in the present* than *of the action itself*; as,

(3) ប្រើសំរាប់ពិពណ៌នាអំពីហេតុការណ៍ក្នុងអតីតកាលនៅពេលដែលយើងនឹកគិតទៅដល់លទ្ធផលរបស់វានៅក្នុងពេលបច្ចុប្បន្ន ច្រើនជាងគិតទៅដល់ សកម្មភាពខ្លួនឯង ដូចជា

to know *sb* + to-infinitive

*Sb* is known + to-infinitive (more common)

to think of sth = គិតទៅដល់ / ពិចារណាអំពីអ្វី១

to think *more* of A *than* of B = គិតទៅដល់ A ច្រើនជាង B

Gopi *has been* all the biscuits (i.e. there aren't any left for you).

Gopi ញ៉ាំនំ biscuits អស់ហើយ (គឺថា. អត់មាននៅសល់សំរាប់អ្នកទៀតទេ)។

***ចូលចំណុចលេខ (2) និង (3) តែមួយ។

www.salarean.com

(2)
ប្រើសំរាប់អំពើកើតចប់ក្នុងអតីតកាល គ្មានពេលវេលាច្បាស់លាស់ គ្រាន់តែមានលទ្ធផលមកពេលបច្ចុប្បន្នតាមន័យតែប៉ុណ្ណោះ។

*I have cut my finger (and it is bleeding now).*
ខ្ញុំមុតម្រាមដៃរបស់ខ្ញុំ (ឥឡូវវាហូរឈាម)។
*I have finished my work (= how I am free).*
ខ្ញុំធ្វើកិច្ចការរួចហើយ។

(4) To denote an action beginning at some time in the past and continuing uo to the present moment (often with since – and for-phrase); as,

(4) ប្រើសំរាប់សំគាល់ពីសកម្មភាពមួយដែលចាប់ផ្តើមកើតឡើងនៅពេលណាមួយដែលក្នុងអតីតកាល ហើយបន្តរហូតមកដល់ពេលបច្ចុប្បន្នកាល (ជាញឹកញាប់គេប្រើជាមួយកន្សោមពាក្យ since ហើយនិង for) ដូចជា

sometime = នៅពេលណាមួយ

up to = រហូតដល់




ប្រើសំរាប់អំពើមួយដែលកើតពីចំណុចណាមួយក្នុងអតីតកាល(អត់ដឹងពេលវេលា)មកដល់ឬមកចប់ត្រង់ចំណុច MS។

since = ប្រាប់ចំណុចចាប់ផ្តើម

since + *point in time* (ចំណុចពេលវេលា)

for + *period of time* (រយៈពេល)

I *have known* him for a long time. ខ្ញុំស្គាល់គាត់អស់រយៈពេលជាយូរមកហើយ។

He *has been* ill since last week. គាត់ឈឺតាំងពីអាទិត្យមុនមក។

We *have lived* here for ten years. យើងបានរស់នៅទីនេះអស់រយៈពេល១០ឆ្នាំហើយ។

We *haven't seen* Padma for several months.
យើងខានឃើញ Padma អស់រយៈពេលជាច្រើនខែហើយ។

***(4) ប្រើសំរាប់អំពើដែលកើតឡើងច្រំដែលរហូតមកដល់ពេល MS (បច្ចុប្បន្ន)

***(4) Repeated action

***ជាទូទៅមាន Adverb of frequency ប្រាប់ចំនួនដង: ២ដង, ៣ដង, ..., ១០ដង (Adverb ប្រាប់ពីចំនួនដងប្រើជាមួយ Present Perfect)។

I have met him twice.
ខ្ញុំជួបគាត់២ដងហើយ។
(***អំពើនេះចប់ហើយក្រោយមកជួបម្តងទៀត តែលទ្ធភាពកើតឡើងនៅមាន។)
(***អំពើ១កើតឡើងច្រំដែលៗតែចប់ហើយ លទ្ធភាពកើតឡើងលែងមានប្រើ Past Simple ប៉ុន្តែបើអំពើ១នោះកើតឡើងច្រំដែលៗហើយលទ្ធភាពនៅមានប្រើ Present Perfect។)

I have written five letters *this morning* .
*ពេលវេលាមិនទាន់ចប់*
ខ្ញុំសរសេរសំបុត្របាន៥ហើយព្រឹកនេះ។




www.salarean.com

***ពេលវេលាមិនទាន់ចប់បានន័យថា យើងឈរនិយាយក្នុងពេលវេលានោះ។

***ប៉ុន្តែបើយើងនិយាយថា ព្រឹកនេះខ្ញុំសរសេរសំបុត្របាន៥ ប៉ុន្តែនិយាយនៅក្នុងពេលព្រឹកបានន័យថា នៅក្នុងពេលដែលពេលព្រឹកមិនទាន់ចប់ គឺប្រើ Present Perfect។ ប៉ុន្តែបើនិយាយថា ព្រឹកមិញនេះខ្ញុំសរសេរសំបុត្របាន៥ និយាយនៅក្រៅពេលព្រឹក គឺប្រើ Past Simple។




I *wrote* 5 letters this morning.

*** (5) Present Perfect ប្រើក្នុង Future ដែលបំផ្លែងរូបភាពមកពី Future Perfect។

I will wait until you *have finished* with the dictionary. ខ្ញុំនឹងរង់ចាំរហូតដល់អ្នកមើលវចនានុក្រមរួច។

↑

I will wait. You *will have finished* with the dictionary.

223. The following adverbs or adverb phrases can also be used with the Present Perfect (apart from those mentioned above): never, ever (in questions only), so far, till now, yet (in negatives and questions), already, today, this week, this month, etc.

223. Adverb ខាងក្រោម ឬ Adverb Phrase ខាងក្រោមក៏អាចត្រូវគេប្រើជាមួយកាល Present Perfect ដែរ (ក្រៅពី Adverb ដែលគេលើកឡើងខាងលើ): never, ever (តែក្នុងប្រយោគសួរទេ), so far (រហូតមកដល់ពេលនេះ), till now (រហូតមកដល់ពេលនេះ), yet [មិនទាន់នៅឡើយ] (នៅក្នុងប្រយោគបដិសេធនិងសំណួរ), already (រួចហើយ), today, this week, this month, etc។

*to day* / *this week* / *this month* } ហៅថារយៈពេលមិនទាន់ចប់

*Apart from* (Preposition) + | *sth* (N) / *doing sth* (N)

*those* | *who ... = អ្នកដែល* / *that ... = អ្វីដែល*

*those* (~~*who*~~ + ~~*be*~~) + | *Past Participle* / *Adjective* / *Prepositional Phrase*

e.g. those (~~who were~~) interviewed......

=> those interviewe......

អ្នកដែលត្រូវគេធ្វើសម្ភាសន៍......

*those* (~~*who were*~~) *responsible* (Adjective) *for the crime ... ...*

=> *those responsible for the crime ... ...*

*អ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ... ...*

*those* (~~*who are*~~) *in prison.*

=> *those in prison* (Prep. Phrase) .

*អ្នកដែលជាប់គុក។*

www.salarean.com

those (~~who are~~) *finding* comfort in themselves … …

=> those *finding* comfort in themselves … …

អ្នកដែលស្វែងរកសេចក្ដីសុខនៅក្នុងខ្លួន … …

…… apart from those *mentioned* ……
Past Participle

…… apart from those (~~which were~~) mentioned……

Note—The Present Perfect is never used with adverbs of past time. We should not say, for example, 'He *has gone* to Kolkata yesterday'. In such cases the Simple Past should be used ('He *went* to Kolkata yesterday').

សំគាល់--Present Perfect មិនដែលប្រើជាមួយនឹង Adverb ដែលប្រាប់ពីពេលវេលាក្នុងអតីតកាលនោះទេ។ ឧទាហរណ៍ យើងមិនគួរនិយាយថា 'He has gone to Kolkata yesterday' ។ នៅក្នុងករណីបែបនេះគេគួរតែប្រើ Past Simple 'He went to Kolkata yesterday'។

Yesterday ជា Adverb ប្រាប់ចំណុចពេលវេលាក្នុងអតីតកាល (Past Simple)។

www.salarean.com

# *PRESENT PERFECT CONTIUOUS TENSE*

224. The Present Perfect Continuous is used for an action which began at sometime in the past and is still continuing; as,

224. Present Perfect Continuous ត្រូវបានគេប្រើសំរាប់អំពើមួយចាប់ផ្ដើមកើតឡើងនៅពេលណាមួយក្នុងអតីតកាលហើយនៅតែកំពុងបន្ត។ ដូចជា

He *has been sleeping* for five hours (and is still sleeping).

គាត់ដេកអស់រយៈពេល៥ម៉ោងហើយ។

They *have been building* the bridge for several months.

ពួកគេបានកសាង(បាននឹងកំពុង)ស្ពានហ្នឹងអស់រយៈពេលជាងច្រើនខែហើយ។

They *have been playing* since four o'clock.

ពួកគេបានលេងតាំងពីម៉ោង៤មក។

***យើងប្រើ Present Perfect Continuous នៅពេលយើងចង់សង្កត់ធ្ងន់លើរយៈពេល។

***គេប្រើ Present Perfect គឺសង្កត់ធ្ងន់លើសកម្មភាព/អំពើ។

225. This tense is also sometimes used for an action already finished. In such cases the continuity of the activity is emphasized as an explanation of something.

225. កាលនេះជួនកាលក៏គេប្រើសំរាប់សកម្មភាពមួយដែលចប់រួចទៅហើយដែរ។ នៅក្នុងករណីបែបនេះ ការបន្តសកម្មភាពត្រូវបានគូសបញ្ជាក់ជាការពន្យល់អំពីអ្វីមួយ។

'Why are your clothes so wet?'—'I *have been watering* the garden'.

«ហេតុអ្វីក៏អាវរបស់អ្នកទទឹកជោគអញ្ចឹង?»--«ខ្ញុំស្រោចទឹកសួន»។

***Present Perfect Continuous***

១. អំពើកើតក្នុងអតីតកាលបន្តមកដល់ពេលកំពុងនិយាយ

២. អំពើកើតចប់រួចហើយ (តែនៅសល់ស្លាកស្នាមឬភស្តុតាង)

***Sequence of Tense***

When + Past Simple – Past Perfect Continuous

When + Past Simple – Past Continuous

ឧទាហរណ៍ថា ម្សិលមិញពេលខ្ញុំទៅដល់ផ្ទះឃើញទឹកលិចពីលើដំបូល។ ទឹកលិចមានពីរករណី:

១. ពេលបើកទ្វារចូលទៅឃើញទឹកកំពុងស្រក់តក់ៗ

When + Past Simple – Past Continuous

២. ពេលបើកទ្វារចូលទៅឃើញទឹកលិចសើមជោកក្ដា

When + Past Simple – Past Perfect Continuous

***កាលណាយើងនិយាយថា យើងចូលទៅដល់ឃើញអំពើមួយកំពុងកើតឡើង បានន័យថាយើងទៅដល់ពាក់កណ្ដាលអំពើនោះ ហើយអំពើនោះកើតឡើងពីពេលណាមកយើងមិនដឹងទេ ប៉ុន្តែយើងទៅដល់ពាក់កណ្ដាលហើយ ហើយវាចប់ក្រោយពេលនោះ។ នេះគឺជានិយមន័យរបស់ Past Perfect Continous។

***តែបើយើងទៅដល់លែងឃើញស្រក់ហើយ ឃើញតែស្នាមសើម នេះគេហៅថាស្លាកស្នាម។ គេប្រើ Past Perfect Continuous។

***Present Perfect Continous គឺជាហេតុការណ៍យើងកំពុងនិយាយ។




www.salarean.com

***Present Perfect Continuous & Past Perfect Continuous គឺមានហេតុការដូចគ្នា តែខុសគ្នាត្រង់ MS (Moment of Speaking)។

www.salarean.com

# *Past Tense*
# *Simple Past Tense*

226. The simple Past is used to indicate an action completed in the past. It often occurs with adverbs or adverb phrases of past time.

226. Past Simple ត្រូវបានគេប្រើសដើម្បីបញ្ជាក់ពីសកម្មភាពមួយដែលចប់នៅក្នុងអតីតកាល។ វាជាញឹកញាប់កើតឡើងដោយមាន Adverbs ឬ Adverb Phrases ប្រាប់ពីពេលវេលាក្នុងអតីតកាល។

***ពេលវេលាក្នុងអតីតកាលហៅថាចំណុចពេលវេលា។

The steamer *sailed yesterday*.

កប៉ាល់ហ្នឹងបើកកាលពីថ្ងៃម្សិលមិញ។

Steamer = កប៉ាល់ប្រើចំហាយទឹក/កប៉ាល់ដុតធ្យូង

I *received* this letter *a week ago*.

ខ្ញុំទទួលបានសំបុត្ររបស់គាត់កាលពីមួយសប្តាហ៍មុន។

She *left* school *last year*.

227. Sometimes this tense used without an adverb of time. In such cases the time may be either implied or indicated by the context.

227. ជួនកាលកាលនេះត្រូវបានគេប្រើដោយមិនមាន Adverb ប្រាប់ពេលវេលាទេ។ នៅក្នុងករណីទាំងនេះ ពេលវេលាអាចត្រូវបានគេយល់ឬត្រូវបញ្ជាក់ដោយបរិបទ។

I *learnt* Hindi in Nagpur.

ខ្ញុំរៀនអក្សរ hindi នៅ Nagpur។

I *didn't* sleep well (i.e., last night).

ខ្ញុំដេកអត់លក់ស្រួលសោះយប់មិញ។

Babar *defeated* Rana Sanga *at Kanwaha*.
*Adverb of place*

Babar វាយយកឈ្នះលើ Rana Sanga នៅ Kanwaha។

228. The Simple Past is also used for past habits; as,

228. Past Simple ក៏ត្រូវបានគេប្រើសំរាប់ទំលាប់ក្នុងអតីតកាលដែរ ដូចជា

He *studied* many hours every day.

គាត់រៀនច្រើនម៉ោងណាស់មួយថ្ងៃៗ។

She always *carried* an umbrella.

គាត់តែងតែកាន់ឆ័ត្រ(យកឆ័ត្រតាមរហូត)។

Past Simple

១. ទំលាប់ក្នុងអតីតកាល

២. អំពើកើតចប់ត្រង់ចំណុចពេលវេលាច្បាស់លាស់មួយ--បើអត់ពេលវេលាជា Present Perfect។

៣. { *អំពើច្រំដែល (លទ្ធផលកើតឡើងលែងមាន)* / *ឬ ប្រើសំរាប់អំពើដែលនិយាយនៅក្រោយ* / *ពេលវេលាដែលមិនទាន់ចប់* } --លទ្ធភាពកើតមានជា Present Perfect

៤. អំពើកើតឡើងបន្តបន្ទាប់គ្នាច្រើនក្នុងអតីតកាល

www.salarean.com

## *Present Simple*

១. ទំលាប់បន្តមកដល់ពេលឥឡូវ
២. ការពិតទូទៅ
៣. ឧទ្ទានស័ព្ទ
៤. ការអត្ថាធិប្បាយកីឡា
៥. ការនិទានរឿង
៦. កាលវិភាគ
៧. Quotation
៨. ជំនួស Future Simple
៩. Headline

## *Present Prefect*

១. អំពើកើតចប់ក្នុងអតីតកាលភ្លាមៗដោយប្រើជាមួយ just
២. អំពើកើតចប់ក្នុងអតីតកាលគ្មានពេលវេលាជាក់លាក់
៣. អំពើកើតឡើងច្រំដែលៗច្រើនដងក្នុងពេលវេលាមិនទាន់ចប់
៤. អំពើកើតឡើងពីអតីតកាលបន្តមកដល់ឬមកចប់ត្រឹមបច្ចុប្បន្ន
៥. ប្រើនៅក្នុង Future គឺជាកាលដែលផ្លាស់ប្តូរមកពី Future Perfect នៅក្នុងពេលដែលគេយកឃ្លាឯករាជ្យទៅតភ្ជាប់គ្នាដោយប្រើ Conjunction: until, til...។

www.salarean.com

# ***PAST CONTINUOUS TENSE***

229. The Past Continuous is used to denote an action going on at some time in the past. The time of the action may or may not be indicated.

229. Past Continuous ត្រូវបានគេប្រើសដើម្បីសំគាល់អំពើមួយដែលកំពុងបន្តនៅពេលណាមួយនៅក្នុងអតីតកាល។ ពេលវេលាដែលអំពើនេះកើតឡើងអាចត្រូវគេបញ្ជាក់ ឬ អាចមិនត្រូវបានគេបញ្ជាក់។

We *were listening* to the radio all evening.

យើងស្តាប់វិទ្យុពេញមួយល្ងាច។

It *was getting* darker.

វាកាន់តែងងឹតទៅៗ។

*The light went out while I was reading*. (*While ទូទៅជាង*)

*I was reading when the light went out.*

*ខ្ញុំកំពុងតែអាន ស្រាប់តែភ្លើងដាច់។*

*Past Simple* + {*while* / *when*} + *Past Continuous*

*When* + *Past Simple* + *Past Continuous* (*ប្រើបានតែwhen*)

(When : more common)

***អំពើមួយកំពុងកើតឡើងអំពើមួយទៀតមកកាត់ផ្តាច់។ អំពើកំពុងកើតឡើងគេហៅថា Backgroud action (អំពើដែលបន្តវែង) នៅពីក្រោយខ្នងអំពើមួយឬច្រើនទៀត។







When I saw him, he *was playing* chess.

ពេលខ្ញុំឃើញគាត់ គាត់កំពុងលេងអុក។

***ឧទាហរណ៍ថា ម្សិលមិញពេលខ្ញុំចូលទៅក្នុងផ្ទះឃើញដំបូលលិចទឹក បានន័យថា បើកទ្វារចូលទៅឃើញស្រក់តក់ៗ ហើយករណី១ទៀតលែងលិចទឹកហើយ ប៉ុន្តែឃើញទឹកសើមពេញក្តារ។ ការចូលទៅឃើញទឹកស្រក់តក់ៗ គឺជាកាល Past Continuous ពីព្រោះយើងទៅទាន់វាកំពុងតែស្រក់ បើវាកំពុងស្រក់ពេលយើងឃើញបានន័យថា វាស្រក់មុននេះបន្តិច ហើយអាចចប់ក្រោយពេលហ្នឹង។ ប៉ុន្តែពេលយើងទៅដល់ឃើញតែសើមគឺប្រើកាល Past Perfect Continuous។

***បើយើងលើកហេតុការណ៍នេះមកដាក់បច្ចុប្បន្នកាល ទាហរណ៍ថា ខ្ញុំឃើញអ្នកឯងទទឹកជោគអញ្ចឹង អ្នកឯងឆ្លើយថា ដើរហាលភ្លៀង ប្រើកាល Present Perfect Continuous។

***ឧទាហរណ៍ថា បើយើងចូលទៅហាងបាយមួយ ពេលទៅដល់អង្គុយហើយហៅម្ហូប រួចអ្នកនិយាយថា អត់ញាំទេ ព្រោះញាំរួចហើយ ប្រើកាល Present Perfect គឺមានទាក់ទងទៅនឹង Result។ ហេតុអ្វីបានអត់ញាំ ព្រោះឆ្អែតរួចហើយ។

***ឧទាហរណ៍ថា បាយជាប់មាត់អ្នក អ្នកឆ្លើយថា ខ្ញុំញាំបាយ (តែពេលនិយាយគ្មានអត់ញាំទេ) ប្រើ Present Perfect Continuous ព្រោះមានស្លាកស្នាម។

www.salarean.com

As in the last two examples above, the Past Continuous and Simple Past were used together when a new action happened in the middle of a longer action. The Simple Past is used for the new action.
ដូចនៅក្នុងឧទាហរណ៍ពីរចុងក្រោយខាងលើ Past Contiuous និង Simple Past ត្រូវបានគេប្រើជាមួយគ្នា នៅពេលដែលអំពើថ្មីមួយកើតឡើងនៅចំកណ្តាលនៃអំពើមួយដែលវែងជាងវា។ Simple Past ប្រើសំរាប់អំពើដែលកើតថ្មីនោះ។

…… *examples* (Noun) *above* (ADV), ……

230. This tense is also used with always, continually, etc. for persistent habits in the Past.
230. កាលនេះក៏គេប្រើជាមួយ always, continually, ។ល។ សំរាប់ទំលាប់ដ៏ចចេសនៅក្នុងអតីតកាល។

He was always *grumbling*. គាត់ហ្នឹងត្អូញត្អែរហេតតែម្តង/មិនស្វាង។

www.salarean.com

# *PAST PERFECT TENSE*

ត្រូវមើល Present Perfect & Past Simple

*Present Perfect*

១. អំពើទើបចប់ថ្មីៗក្បែរ MS--ពាក្យ just




២. អំពើដែលកើតចប់ក្នុងអតីតកាលគ្មានពេលវេលាច្បាស់លាស់




៣. អំពើកើតក្នុងអតីតកាលបន្តមកដល់បច្ចុប្បន្នកាលឬមកដល់ឬចប់នៅ MS។




៤. សំរាប់ Future (មកពី Future Perfect)

*PAST SIMPLE*

១. អំពើកើតចប់ក្នុងអតីតកាលមានពេលវេលាច្បាស់លាស់




២. អំពើកើតឡើងជាបន្តបន្ទាប់ក្នុងអតីតកាល







I had just had dinner.

ខ្ញុំទើបញ៉ាំបាយហើយអំបាញ់មិញ។

(គិតពីពេលនិយាយត្រឡប់ទៅក្រោយ)

I met Sok at 6 o´clock yesterday. He had just had dinner.

ខ្ញុំជួបសុកនៅម៉ោង៦ម្សិលមិញ។ គាត់ទើបញ៉ាំបាយល្ងាចហើយ។

(គិតពីពេលជួបគ្នានៅម៉ោង៦ទៅក្រោយ)

231. The Past Perfect describes an action completed before a certain moment in the past; as,

231. Past Perfect ពិពណ៌នាពីសកម្មភាពមួយដែលចប់មុនខណៈពេលពិតដ៏ប្រាកដមួយនៅក្នុងអតីតកាល ដូចជា

www.salarean.com

I met him in New Delhi in 1996. I had seen him last five years before.

ខ្ញុំបានជួបគាត់នៅទីក្រុង New Delhi នៅឆ្នាំ១៩៩៦។ ខ្ញុំបានឃើញគាត់ជាលើកចុងក្រោយកាលពី៥ឆ្នាំមុន។ (គិតពី ឆ្នាំ១៩៩៦)

I last saw him 5 years before.




I met him in *New Delhi in 1996*. I had last seen him 5 years before.




Sok: "I have learned English for 3 monsths."

ខ្ញុំរៀនអង់គ្លេស៣ខែហើយ។







Sok said he had learned English for 3 months.




I lived there for 3 years.

The king *sent* (អំពើទី១) them to find a happy man and when then they *had found* (អំពើទី២) him to bring back his shirt.

*មិនមែនជា Past Perfect ដោយសារវាប្តូរពី Future Perfect*

ស្តេចបានបញ្ជាពួកគេឲ្យទៅស្វែងរកមនុស្សសប្បាយហើយពេលរកឃើញឲ្យយកអាវវាមក។

He sent me here to buy a packet of cigarette.

គាត់ប្រើខ្ញុំឲ្យមកទិញបារីមួយកញ្ចប់។

232. If two actions happened in the past, it may be necessary to show which action happended earlier than the other. The Past Perfect is mainly used in such situations. The Simple Past is used in one clause and the Past Perfect in the other; as,

232. ប្រសិនបើអំពើពីរកើតឡើងនៅក្នុងអតីតកាល វាគឺជាការចាំបាច់ណាស់ដែលត្រូវបង្ហាញថាតើអំពើមួយណាកើតមុនអំពើមួយផ្សេងទៀត។ Past Simple គេប្រើជាពិសេសក្នុងស្ថានការណ៍បែបហ្នឹងហើយ។ Simple Past ត្រូវបានគេប្រើនៅក្នុងឃ្លាមួយហើយ Past Perfect ប្រើនៅក្នុងឃ្លាមួយទៀត។

Maily = ជាសំខាន់/ជាពិសេស

*When* I *reached* (អំពើទី២) the station the train *had started* (អំពើទី១) (so I couldn't get into the train).

ពេលខ្ញុំទៅដល់ស្ថានីយ៍រថភ្លើងចាប់ផ្តើមចេញដំណើរបាត់ទៅហើយ។ (ដូច្នេះ ខ្ញុំមិនអាចជិះរថភ្លើងបានទេ) [(ចេញទៅមុនពេលយើងមកដល់) ទៅផុតយូរហើយ។]

www.salarean.com

I *had done* (អំពើទី១) my exercise *when* Hari *came* (អំពើទី២) to see me.

ខ្ញុំធ្វើលំហាត់រួចហើយនៅពេលដែល Hari មកលេង។ (ចប់មុនពេល Hari មកដល់)

I *had written* the letter *before* he *arrived*.

ខ្ញុំសរសេរសំបុត្ររួចហើយមុនពេលគាត់បានមកដល់។

1. Past Perfect + *before* + Past Simple
2. *After* + Past Perfect + Past Simple

***Present Perfect និង Present Perfect Continuous ខុសគ្នាត្រង់ គេប្រើ Present Perfect Continuous នៅពេលដែលគេសង្កត់ធ្ងន់លើ*រយៈពេល*។ ហើយគេប្រើ Present Perfect នៅពេលដែលគេសង្កត់ធ្ងន់ពីអំពើ/សកម្មភាព ដូច្នេះ ភាពខុសគ្នារបស់ Past Perfect និង Past Perfect Continuous ក៏ដូចគ្នាដែរ។

www.salarean.com

# *PAST PERFECT CONTINUOUS TENSE*

233. The Past Perfect Continuous is used for an action that began before *a certain point* in the past and continued up to that time; as,

233. Past Perfect Continuous ត្រូវបានគេប្រើសំរាប់អំពើមួយដែលចាប់ផ្តើមកើតឡើង *មុនចំណុចពេលវេលាពិតប្រាកដមួយ* នៅក្នុងអតីតកាលហើយបន្តរហូតមកដល់ត្រង់ចំណុចពេលវេលានោះ។

***Past Perfect Continuous និងPresent Perfect Continuous គេច្រើនប្រើសំរាប់អំពើបណ្តោះអាសន្ន (Temperary Action)។

***អំពើយូរអង្វែង (Long Term Action) គេច្រើនប្រើទំរង់ Perfect Simple។

***ឧទាហរណ៍ថា ជួបមិត្តភក្តិ ហើយសួរថា អ្នកឯងធ្វើអ្វីនៅឯណា ហើយគេឆ្លើយថា តាំងពីចេញពីរៀនមក ធ្វើទាហានរហូត ។ ពេលកំពុងនិយាយគ្នាប្រើកាល Present Perfect ។ រួចហើយពេលត្រឡប់មកដល់ផ្ទះ និយាយប្រាប់អ្នកផ្ទះថា បានជួបមិត្តម្នាក់ ធ្លាប់រៀនជាមួយគ្នា ហើយថា វាធ្វើទាហានរហូត។ ធ្វើទាហានរហូតមកដល់ត្រឹមពេលនិយាយគ្នាម្សិលមិញ។ កន្លែងនិយាយគ្នាគេហៅថា ចំណុចពេលវេលាដែលអំពើហ្នឹងមកដល់ឬមកចប់។




ខ្ញុំទៅផ្ទះមិត្តខ្ញុំម៉ោង៦.៣០ ម្តាយមិត្តខ្ញុំថា គាត់ចេញទៅបាត់ហើយ គឺប្រើ Past Perfect គឺដោយសារទៅដល់ម៉ោង ៦.៣០ គឺជាចំណុចគោលដៅដែលយើងគិតពី៦.៣០ទៅ អំពើមួយទៀតបានកើតមុននេះ។




***ឧទាហរណ៍ ខ្ញុំមានផ្កាកមួយនៅរបងផ្ទះ ពេលទៅមើលស្រាប់តែបាត់ ហើយអ្នកជិតខាងប្រាប់ថា ឃើញមនុស្សម្នាក់ក្រវែលជិតវាយូរហើយ។

អណាពើចប់ត្រឹមគេលួចផ្កាកនោះយកទៅ។




www.salarean.com

At that time he *had been writing* a novel for two months.
នៅពេលនោះគាត់បានសរសេរកំណាព្យអស់រយៈពេល២ខែ។
(គេចង់សង្កត់ធ្ងន់លើរយៈពេល គេចង់និយាយថាមកដល់ពេលនោះ គឺពេល២ខែហើយ។

When Mr. Mukerhi came to the school *in 1995*, Mr. Anand had already been teaching there for five years.
នៅពេលលោក Mukerji មកសាលានេះនៅឆ្នាំ១៩៩៥ លោក Anand បានបង្រៀននៅទីនេះអស់រយៈពេល ៥ឆ្នាំទៅហើយ។ (៥ឆ្នាំគិតមកដល់លោក Mukerji ទៅដល់សាលានេះនៅឆ្នាំ១៩៩៥)




www.salarean.com